Nº 4

# ការឃោសនាបោះឆ្នោត

**សំណួរៈ** **តើការឃោសនាបោះឆ្នោតមានទិសដៅយ៉ាងដូចម្តេចខ្លះ ?**

**ចម្លើយៈ** អនុលោមតាម ច.ប.ត.រ ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត។

ដូច្នេះការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើងជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។ (ប.ន.៧.១)

**សំណួរៈ** **តើសកម្មភាពណាខ្លះ ដែលចាត់ទុកថា ជាការឃោសនាបោះឆ្នោតដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយ ?**

**ចម្លើយៈ** សកម្មភាពឃោសនាបោះឆ្នោតដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ឬរិះគន់គោលនយោបាយ ឬកម្មវិធីនយោបាយគណបក្សណាមួយមានដូចជា ÷

-ការជួបប្រជុំជាសាធារណៈ របស់គណបក្សនយោបាយ ឬបេក្ខជន។ (ប.ន.៧.១.១)

-ការជួបជុំ ឬការរៀបចំជាក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ឬការឃោសនាតាមផ្ទះ ។ (ប.ន.៧.១.២)

-ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។ (ប.ន.៧.១.៣)

-ការផ្សព្វផ្សាយតាមរលកអាកាស ឬស្រែកជាពាក្យស្លោកខ្លីៗ តាមឧបករណ៍បំពងសម្លេង ឬដោយចាក់ម៉ាញ៉េ ។ (ប.ន.៧.១.៤)

-ការផ្សព្វផ្សាយតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ។ (ប.ន.៧.១.៥)

-សកម្មភាពបិទផ្សាយនូវរូបភាពឃោសនា ។ (ប.ន.៧.១.៦)

-សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ។ (ប.ន.៧.១.៧)

-សកម្មភាពចែកចាយមួក សម្លៀកបំពាក់ ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារៈផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតជូនអ្នកបោះឆ្នោត ។ (ប.ន.៧.១.៨)

-សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងតម្លើងបន្ទះក្តារបិទប្រកាសផ្សាយ ។ (ប.ន.៧.១.៩)

-ការប្រគំតន្ត្រីដោយការដើរជាក្បួន ឬនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ។ (ប.ន.៧.១.១០)

-ការរៀបចំកម្មវិធីប្រកួតកីឡា ។ (ប.ន.៧.១.១១)

**សំណួរៈ** **ជាគោលការណ៍ តើការឃោសនាបោះឆ្នោតត្រូវធ្វើក្នុងរយៈប៉ុន្មានថ្ងៃ ?**

**ចម្លើយៈ** ការឃោសនាបោះឆ្នោតត្រូវបើករយៈពេល ៣១ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ (ប.ន.៧.២) ប៉ុន្តែដំណើរការនៃការឃោសនាបោះឆ្នោតមានរយៈពេលតែ ៣០ថ្ងៃ ប៉ុណ្ណោះ ។ (ប.ន.៧.២.១)

**សំណួរៈ** **តើការឃោសនាបោះឆ្នោតត្រូវចាប់ផ្តើមពីថ្ងៃណា ហើយបញ្ចប់នៅថ្ងៃណា ?**

**ចម្លើយៈ** ការឃោសនាបោះឆ្នោត ចាប់ផ្តើមពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៨ ហើយបញ្ចប់នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨ ។ ការឃោសនាត្រូវចប់ ២៤ម៉ោង មុនថ្ងៃបោះឆ្នោត ។

**សំណួរៈ** **គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ តើត្រូវចាប់ផ្តើមពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ហើយត្រូវឈប់សម្រាកពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ?**

**ចម្លើយៈ** គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោង ៦ ព្រឹក ដល់ម៉ោង ១០យប់ ។ (ប.ន.៧.២.២) ហើយត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ១០យប់ ដល់ម៉ោង ៦ព្រឹក ។ (ប.ន.៧.២.៣) ដោយឡែកចំពោះសកម្មភាពឃោសនាដោយឧបករណ៍បំពងសម្លេង ត្រូវហាមឃាត់ចាប់ពីម៉ោង ១២ថ្ងៃត្រង់ ដល់ម៉ោង ២រសៀល ។

**សំណួរៈ** **តើការបោះឆ្នោតលើកនេះ អាចធ្វើការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិទាក់ទងនឹងដំណើរការបោះឆ្នោតបានដែរឬទេ ?**

**ចម្លើយៈ** អាចធ្វើបាន ប៉ុន្តែរាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិទាក់ទងទៅនឹងដំណើរការបោះឆ្នោតត្រូវបញ្ឈប់ ៥ថ្ងៃ មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត ។ (ប.ន.៧.២.៥)

**សំណួរៈ** **តើការស្ទង់មតិគឺជាអ្វី ?**

**ចម្លើយៈ** ការស្ទង់មតិ គឺជាការប្រើបញ្ជីសំណួរដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីការបោះឆ្នោត ។ ការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិបញ្ជាក់អំពីប្រភពផ្តល់ព័ត៌មាន ពេលវេលា ចំនួនប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសមកស្ទង់មតិ និងកំរិតលម្អៀងនៃលទ្ធផល ។ (ប.ន.៧.២.៥)

**សំណួរៈ** **គ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ទាំងអស់ ក្នុងអំឡុងពេល ២៤ម៉ោង មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ចុះបើមានជនណាប្រព្រឹត្តល្មើសនឹងបម្រាមនេះ តើត្រូវទទួលពិន័យដែរ ឬទេ ?**

**ចម្លើយៈ** មិនអនុញ្ញាតឱ្យធ្វើសកម្មភាពឃោសនាអ្វីទាំងអស់ក្នុងអំឡុងពេល ២៤ម៉ោង មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ហើយត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងបម្រាមនេះ។ ក្នុងករណីដែលនៅពុំព្រមអនុវត្តតាម ត្រូវដកហូតប័ណ្ណបោះឆ្នោតសម្រាប់រយៈពេល ៥ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥លានរៀល ដល់ ១០លានរៀល ។

**សំណួរៈ** **ចំពោះគណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្រសួងមហាផ្ទៃហើយ តើគណបក្សនយោបាយទាំងនោះមានសិទ្ធិអាចធ្វើអ្វីបានខ្លះ ?**

**ចម្លើយៈ** គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ អាចរៀបចំកិច្ចប្រជុំអំពីកម្មវិធីនយោបាយរបស់ខ្លួននៅទីកន្លែងឯកជនបានគ្រប់ពេល និងមានសិទ្ធិលើកស្លាកគណបក្សគ្រប់ពេលនៅលើទីតាំងឯកជន ឬផ្ទះឯកជន ដោយមានការអនុញ្ញាតពីម្ចាស់ទីកន្លែងនោះ ។ (ប.ន.៧.៣)

**សំណួរៈ** **តើស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈបានដែរឬទេ ?**

**ចម្លើយៈ** ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈបាន ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ និងសណ្តាប់ធ្នាប់។ (ប.ន.៧.៣.១)

**សំណួរៈ** **ទាក់ទិនជាមួយអគារ ឬការិយាល័យរដ្ឋ តើគណបក្សនយោបាយមានសិទ្ធិលើក ឬបិទស្លាកសញ្ញាគណបក្ស និងសម្ភារៈឃោសនាបានដែរ ឬទេ ?**

**ចម្លើយៈ** ចំពោះអគារ ឬការិយាល័យរដ្ឋ គណបក្សនយោបាយមិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទស្លាកសញ្ញាគណបក្ស និងសម្ភារៈឃោសនាទេ ។ (ប.ន.៧.៣.២)

**សំណួរៈ** **រាល់ប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារឃោសនា តើគណបក្សនយោបាយត្រូវប្រមូលយកមកវិញទេ ក្រោយថ្ងៃបោះឆ្នោតហើយ ?**

**ចម្លើយៈ** ស្លាកសញ្ញា ឬសម្ភារៈឃោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។ (ប.ន.៧.៣.៣)

គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។ (ប.ន.៧.៣.៤)

**សំណួរៈ** **ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត តើគេអាចរាប់បញ្ចូលទៅក្នុងសកម្មភាពឃោសនាបោះឆ្នោតដែរ ឬទេ ?**

**ចម្លើយៈ** ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្ដល់ជូននូវយានជំនិះឱ្យអ្នកបោះឆ្នោតជិះ មិនរាប់បញ្ចូលទៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈជាឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នឹងការឃោសនាបោះឆ្នោត ។ (ប.ន.៧.៤)

ការស្លៀកពាក់ (សំលៀកបំពាក់ មួក)ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា ឬសារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់នៅទីសាធារណៈ ក៏មិនរាប់បញ្ចូលទៅក្នុងសកម្មភាពឃោសនាបោះឆ្នោតដែរ លើកលែងតែការស្លៀកពាក់នោះ ស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬស្ថិតនៅក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត ។ (ប.ន.៧.៥)

**សំណួរៈ** **ក្នុងការធ្វើសកម្មភាពឃោសនាបោះឆ្នោត តើការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនបែបណាខ្លះដែលត្រូវហាមឃាត់ ?**

**ចម្លើយៈ** ហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។ (ប.ន.៧.៤.១)

**សំណួរៈ** **មធ្យោបាយដឹកជញ្ជូនណាខ្លះ ដែលយើងសម្គាល់ថាជាសម្បត្តិរបស់រដ្ឋ ?**

**ចម្លើយៈ** មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ត្រូវបានកំណត់ដូចជា ÷

រថយន្ត ទោចក្រយានយន្ត និងជលយាន (យានធ្វើដំណើរតាមផ្លូវទឹក) គ្រប់ប្រភេទដែលប្រើប្រាស់ស្លាកសញ្ញា រាជការ រដ្ឋ ន.ប ខ.ម ឬរាជរដ្ឋាភិបាល ។ (ប.ន.៧.៤.២)

**សំណួរៈ** **តើប្រការណាខ្លះ ដែលហាមឃាត់មិនឱ្យមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ ធ្វើសកម្មភាពក្នុងជំណាក់កាលឃោសនាបោះឆ្នោត?**

**ចម្លើយ:** ប្រការដែលហាមឃាត់ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ ធ្វើសកម្មភាពក្នុងដំណាក់កាលឃោសនាបោះឆ្នោតដូចជា÷

-មិនត្រូវប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជា ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ។

-មិនត្រូវប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសម្លេងឆ្នោត ។

-មិនត្រូវចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយណាឡើយ ។(ប.ន.៧.៦)

**សំណួរ: តើសកម្មភាពណាខ្លះ ដែលត្រូវចាត់ទុកថាជាការចូលរួមយ៉ាងសកម្មនោះ?**

**ចម្លើយ:** ការចូលរួមសកម្មដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ដូចតទៅ÷

-ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោត នៃគណបក្សនយោបាយណាមួយ ។(ប.ន.៧.៦.១)

-ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រាដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។(ប.ន.៧.៦.២)

-ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។(ប.ន.៧.៦.៣)

-ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។(ប.ន.៧.៦.៤)

-ការធ្វើសកម្មភាពចែកចាយសម្ភារៈឃោសនាបោះឆ្នោត ដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។(ប.ន.៧.៦.៥)

-ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។(ប.ន.៧.៦.៦)

-ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសម្លេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។ (ប.ន.៧.៦.៧)

**សំណួរ:** **តើមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាបានដែរ ឬទេ ? នៅពេលណា ?**

**ចម្លើយ:** អាចចូលរួមបាន បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងធ្វើការងារ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន ឬ/និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ ។

បើមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ ដែលប្រព្រឹត្តល្មើស នឹងត្រូវទទួលទោសតាមច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ (ប.ន.៧.៧)

**សំណួរ:** **ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា តើត្រូវប្រកាន់ជំហរបែបណា ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនេះ ?**

**ចម្លើយ:** អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀង នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ (ប.ន.៧.៨)

**សំណួរ:** **តើសកម្មភាពណាខ្លះ ដែលអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិ ត្រូវចៀសវាង ?**

**ចម្លើយ:** អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ដោយប្រយោលក្តីដូចជា ÷

-ផ្តួចផ្តើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.១)

-ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.២)

-ផ្ដល់មធ្យោបាយជាថវិកា សម្ភារៈ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.៣)

**សំណួរ:** **តើការផ្ដួចផ្ដើម ឬការចូលរួមឃោសនា ការចេញសេចក្ដីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀង ការផ្ដល់មធ្យោបាយជាថវិកា សម្ភារៈ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ នោះមានលក្ខណៈដូចម្ដេចខ្លះ ?**

**ចម្លើយ:** **ការផ្ដួចផ្ដើម ឬការចូលរួមឃោសនារួមមាន ÷**

-ការបញ្ចុះបញ្ចូល ឬការប្រមូលផ្ដុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.១.១)

-ការចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.១.២)

-ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារៈឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.១.៣)

-ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។ (ប.ន.៧.៨.១.៤)

**ការចេញសេចក្ដីថ្លែងការណ៍ ឬការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀងរួមមាន÷**

-ការសម្ដែងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ (ប.ន.៧.៨.២.១)

-ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្ដល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ (ប.ន.៧.៨.២.២)

-ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យបន្ទុះបង្អាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ (ប.ន.៧.៨.២.៣)

-ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តផ្ទាល់ខ្លួន ឬរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួនដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ (ប.ន.៧.៨.២.៤)

**ការផ្ដល់មធ្យោបាយជាថវិកា សម្ភារៈ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ រួមមាន÷**

-ការផ្ដល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ បេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.៣.១)

-ការផ្ដល់ថវិកា សម្ភារៈ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.៣.២)

-ការផ្ដល់ថវិកា សម្ភារៈ និងបរិក្ខារសម្រាប់ការដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្ដែងសិល្បៈ និងការបោះពុម្ពសម្ភារៈឃោសនា ទោះដោយផ្ទាល់ក្ដី ឬប្រយោលក្ដី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ (ប.ន.៧.៨.៣.៣)

**សំណួរ: តើគណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវធ្វើដូចម្ដេច ដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌នោះ ?**

**ចម្លើយ:** ជាសំខាន់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ដែលអនុម័តដោយ គ.ជ.ប ។ (ប.ន.៧.១១)

-គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវតែគោរព ច.ប.ត.រ ។ (ប.ន.៧.១១.១)

- គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវតែគោរព ប.ន.ត.រ និងសេចក្ដីណែនាំផ្សេងៗ ដែលបានអនុម័តដោយ គ.ជ.ប ។ (ប.ន.៧.១១.២)

-គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ ។ (ប.ន.៧.១១.៣)

-គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវតែអនុវត្តតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ (ប.ន.៧.១១.៤)

-គណបក្សនយោបាយ បេក្ខជន ឬតំណាង មិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលនូវសម្ភារៈឯកសារផ្សព្វផ្សាយការឃោសនាបោះឆ្នោតរបស់គណបក្ស ឬ /និងបេក្ខជនដទៃឡើយ ។ (ប.ន.៧.១១.៥)

-គណបក្សនយោបាយ បេក្ខជន ឬតំណាង មិនត្រូវជម្រុញឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបំភិតបំភ័យ ក្នុងអំឡុងពេលធ្វើការឃោសនាបោះឆ្នោតឡើយ ។ (ប.ន.៧.១១.៦)

-គណបក្សនយោបាយ បេក្ខជន ឬតំណាង ឬជនណាក៏ដោយ មិនត្រូវផ្តល់វិភាគទាន ជូនសគុណ ចែកអំណោយ ឬវង្វាន់លើកទឹកចិត្ត ជាប្រាក់កាស សម្ភារៈ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។ (ប.ន.៧.១១.៧)

-គណបក្សនយោបាយ បេក្ខជន ឬតំណាង មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យបុគ្គលណាម្នាក់ ឬច្រើននាក់ ឬក្រុមណាមួយ ឬច្រើនក្រុម ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដើម្បីឱ្យអ្នកទាំងនោះ ឬក្រុមទាំងនោះ គាំទ្រខ្លួន ឬបំបាក់ទឹកចិត្ត បុគ្គលទាំងនោះ ឬក្រុមទាំងនោះ ឱ្យឈប់គាំទ្រដល់គណបក្សនយោបាយ ឬបេក្ខជនដទៃឡើយ ។ (ប.ន.៧.១១.៨)

**សំណួរៈ តើការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្តនោះមានលក្ខណៈបែបណាខ្លះ ?**

**ចម្លើយៈ** ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ÷

-ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។ (ប.ន.៧.១១.៨.១)

-ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថានឹងធ្វើទារុណកម្ម ។ (ប.ន.៧.១១.៨.២)

-ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរ ។ (ប.ន.៧.១១.៨.៣)

-ការរំលោភដោយពាក្យសំដីថា នឹងធ្វើទុក្ខទោសដល់រាងកាយ ។ (ប.ន.៧.១១.៨.៤)

-ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។ (ប.ន.៧.១១.៨.៥)

-ការលើកឡើងជាពាក្យសំដី ឬជាលាយលក្ខណ៍អក្សរ ដោយយកព្រឹត្តិការណ៍គួរឱ្យតក់ស្លុត ពីអតីតកាលមកដំណាល ដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ឬក្រុមណាមួយ ។ (ប.ន.៧.១១.៨.៦)

-ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាល ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលណាម្នាក់ ។ (ប.ន.៧.១១.៨.៧)

-ការយកសាកសពសត្វធាតុ ឬឧបករណ៍ណាមួយ ឬធ្វើសញ្ញាណាមួយ ទៅដាក់មុខផ្ទះជនណាម្នាក់ ឬក្រុមណាមួយ ដែលអាចធ្វើឱ្យជននោះ ឬក្រុមនោះមានការភ័យខ្លាច ដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូន គ្រួសាររបស់ខ្លួន ។ (ប.ន.៧.១១.៨.៨)

-ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬគ្រួសាររបស់ខ្លួន ។ (ប.ន.៧.១១.៨.៩)

-ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង ។ (ប.ន.៧.១១.៨.១០)

-ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬការធ្វើឱ្យខូចប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។ (ប.ន.៧.១១.៨.១១)

-ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំឱ្យធ្វើសម្បថ ឬផ្តិតមេដៃ សន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។ (ប.ន.៧.១១.៨.១២)

-ការប្រមូល ឬដកហូតឯកសារបញ្ជាក់អត្តសញ្ញាណ ដែលត្រូវប្រើសម្រាប់បោះឆ្នោត ។ (ប.ន.៧.១១.៨.១៣)

**សំណួរ:** **តើគណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ដែលប្រព្រឹត្តផ្ទុយនឹងបទបញ្ញត្តិខាងលើនឹងទទួលទោសបែបណា ?**

**ចម្លើយ:** ពិតណាស់ ! គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ដែលប្រព្រឹត្តផ្ទុយនឹងចំណុចទាំងឡាយដែលបានរៀបរាប់ខាងលើ នឹងត្រូវទទួលទោសតាមច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ (ប.ន.៧.១២)